ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រ.ក/លេខ០៣.០៥៩/០៨ គ.ជ.ប.អគ្គ.ពស

ភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៨

# គ.ជ.ប ប្រកាសឱ្យប្រើបទបញ្ជា និងនីតិវិធីសម្រាប់ការ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ផ្នែកទី២

នៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសឱ្យប្រើជាផ្លូវការ នូវបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ផ្នែកទី២ ដែលមានពីជំពូកទី៧ ទី៨ ទី៩ ទី១០ ទី១១ ទី១២ និងឧបសម្ព័ន្ធចំនួន ៦។

លោក ជិន សារិន នាយកខុទ្ទកាល័យ អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា បទបញ្ជា និងនីតិវិធីផ្នែកទី២នេះ គ.ជ.ប គ្រោងនឹងបោះពុម្ពចំនួន ២០០០ ច្បាប់ ដើម្បីចែកចាយដល់ លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ខុទ្ទកាល័យព្រះមហាក្សត្រ អគ្គលេខាធិការដ្ឋានរដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ សាលាខេត្ត ក្រុង មជ្ឈមណ្ឌលជាតិតម្កល់ឯកសារ គណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនឹងការបោះឆ្នោត ។ លោកបានបន្ថែមថា បទបញ្ជា និងនីតិវិធីនេះក៏នឹងដាក់បញ្ចូលផងដែរនៅលើទំព័រវិបសាយរបស់ គ.ជ.ប ដែលមានអាសយដ្ឋាន www.necelect.org.kh ។

BtmanbEnmsmTnakTngTrsBe l x³ 023 214 374 / 012 855 018 E-mail: necinfo@forum.org.kh, Web-site : www.necelect.org.kh